បូវឃើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីតធីត
BOWKER GARMENT FACTORY (CAMBODIA) COMPANY LIMITED

# កិច្ចព្រមព្រៀង

**Agreement Letter**

**រវាង Between**

**ក្រុមហ៊ុន បូវឃើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា)ខមភេនី លីមីតធីត**

**Bowker Garment Factory (Cambodia) Co., Ltd**

**និង And**

**តំណាងកម្មករ និងតំណាងសហជីព ប្រចាំក្រុមហ៊ុនបូវឃើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា)ខមភេនី លីមីតធីត**

**Worker representative of Bowker Garment Factory (Cambodia) Co., Ltd**

ដោយសារបញ្ហាការផ្គត់ផ្គង់វត្ថុធាតុដើមមិនបានគ្រប់គ្រាន់ ដោយសារវិបត្តិជំងឺ កូវីដ ១៩ ទើបក្រុមហ៊ុន **បូវឃើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា)ខមភេនី លីមីតធីត** បានធ្វើការប្រជុំពិភាក្សាជាមួយតំណាងកម្មករ និង តំណាងសហជីពប្រចាំក្រុមហ៊ុន ដើម្បីរៀបចំការព្យួរការងាររបស់កម្មករនិយោជិតទាំងអស់នៅអគារផលិតកម្ម អេ (A) ចំនួន ១៤ ក្រុម និង ផ្នែកផ្សេងៗទៀត មានដូចជា ផ្នែកឃ្លាំងសម្ភារៈ ឃ្លាំងក្រណាត់ ឃ្លាំងបង្ហើយការ ឃ្លាំងកាតុង ផ្នែកពិនិត្យ វេចខ្ចប់ ជាងម៉ាស៊ីន និងផ្នែកការិយាល័យផងដែរ សរុបចំនួន ៤៥៦នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបបច្ចុប្បន្ន (២២៣០នាក់) ។ ចាប់ផ្តើមព្យួរពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២០ នេះតទៅ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២០ ដែលមានរយៈពេលសរុប ២ខែ។ ក្នុងនោះផ្នែកធនធានមនុស្សបានពន្យល់បន្ថែមអំពីលក្ខខណ្ឌនៃការព្យួរ គឺអនុវត្តតាមសេចក្តីប្រកាសលេខ ០៤៥ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងកាតព្វកិច្ចរបស់កម្មករ និយោជិតដើម្បីទទួលបានប្រាក់ឧបត្ថមពីខាងក្រុមហ៊ុន និងរាជរដ្ឋាភិបាល ក្នុងរយៈពេលនៃការព្យួរការងារនេះ។

ក្នុងករណីមានការផ្គត់ផ្គង់ការងារគ្រប់គ្រាន់ឡើងវិញ ក្រុមហ៊ុននឹងធ្វើការទំនាក់ទំនងបងប្អូនកម្មករ និយោជិតអោយចូលបំរើការងារវិញមុនពេលកំណត់ ២ ខែ។

កិច្ចព្រមព្រៀងនេះធ្វើឡើងក្នុងគោលការណ៍ស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ ឈរលើគោលការណ៍នៃសេចក្តីប្រកាសរបស់ក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០៤៥ ដែលខាងកម្មករនិយោជិត នឹងទទួលបានទឹកប្រាក់ចំនួន ៣០ដុល្លាអាមេរិកពីខាងក្រុមហ៊ុន និង ៤០ដុល្លាដុល្លាអាមេរិកពីខាងរាជរដ្ឋាភិបាលក្នុងមួយខែ។ (ដូចមានភ្ជាប់ជាមួយស្នាមមេដៃស្ម័គ្រចិត្តរបស់តំណាងកម្មករ និង តំណាងសហជីព)

According to insufficient raw material supplied caused by COVID-19 , Bowker Garment Factory (Cambodia) Co., Ltd held a meeting with worker representative and unions of the company to discuss on work suspension all workers at Building (A) 14 lines, and other department section such as Heat Transfer, Embroidery, Supermarket, Accessary warehouse, Fabric warehouse, Carton warehouse, QC, Packing, mechanic and office staff as well totally 456 of total currently workers (2230 workers) , start from 1st July 2020 to 31st August 2020, total 2 months. In term of this HR department has educate the suspension condition follow Prakas no. 045 issue by Ministry of Labor and the obligation of workers employees to get support allowance from company and government in this suspension period.

In case of the raw material back to sufficient company will call to all employee back to work earlier.

This Agreement had conduct by voluntary without any force, follow the Prakas from Ministry of Labor No. 045 which suspension workers will get 30 USD from Company and 40 USD from Government in a month. (Attached with Thumb print of worker representative, unions, and workers)

ថ្ងៃសៅរ៍ ទី ១៥ រោជ ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

Saturday, 15 roch on Ah Sat in Jut Tosak 2564 BC

បែកចាន,ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០២០

Bek Chan, 20th June 2020

នាយកគ្រប់គ្រងទូទៅ

**General Manager**